01345455

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception):
05 / 11 / 2016
ម៉ោង (Time/Heure): 15:20
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

## កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

### សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

### ថ្ងៃ ចន្ទ ទី ២៣ ខែ ឧសភា ឆ្នាំ ២០១៦

### សវនាការលើអង្គសេចក្តី - ថ្ងៃ ៤១០

រៀបចំដោយ៖ លោក ឯម ហ៊ីយ និង លោក Roger PHILLIPS

| **កំណត់ហេតុអ្នកចូលរួម** |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Claudia FENZ , ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី, ចៅក្រម Martin KAROPKIN |
| ក្រឡាបញ្ជី ៖លោក ឯម ហ៊ីយ , លោក Roger PHILLIPS |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក សេង លាង, លោក Vincent De Wilde d' ESTMAEL, លោក Dale LYSAK , លោក Nicholas KOUMJIAN |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក Victor KOPPE, លោក សុន អរុណ,លោក លីវ សុវណ្ណា |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន |
| ក្រុមមេធាវីប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន៖ លោកស្រី ទូច វរល័ក្ស, លោក Calvin SAUNDERS |

| | |
|---|---|
| មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖ លោកស្រី Marie GUIRAUD លោក ពេជ អង្គ ,លោក វ៉ែន ពៅ | |
| ដើមបណ្ដឹង/សាក្សី/អ្នកជំនាញ៖ សួស ធី (2TCW-816) | |
| មេធាវីប្រឹក្សា៖ លោក មឿន សុវណ្ណ | |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អរុណ, លោកស្រី ស្វ សុទ្ធាវី | |
| ផ្សេងៗ៖ លោក កែវ វ៉ាត , កញ្ញា យស សេរីរ័ត្ន , លោកស្រី សំ មករា, កញ្ញា Hannah KIM | |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៦ | ចាប់ផ្ដើមម៉ោង៖ ០៩.០៨ | បញ្ចប់ម៉ោង៖ ១៣.៤០ |
| សម្រាកពេលព្រឹក | ចាប់ផ្ដើមម៉ោង៖ ១០.៥០ | បញ្ចប់ម៉ោង៖១៣.៣៧ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ១ ម៉ោង ៤៥ នាទី |

**កិច្ចដំណើរការនីតិវិធីផ្សេងទៀត**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្ដើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី | អង្គជំនុំជម្រះ<br>ក្រឡាបញ្ជី | ០៩.០៨ | ០៩.១០ |
| សំណើរបស់ នួន ជា ស្នើសុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ | មេធាវីការពារក្ដី នួន ជា | ០៩.១០ | ០៩.១២ |
| អង្គជំនុំជម្រះចេញសេចក្ដីសម្រេចផ្ទាល់មាត់លើសំណើរបស់សហព្រះរាជអាជ្ញាដែលបានស្នើសុំឱ្យទទួលយកឯកសារ E319/36 | អង្គជំនុំជម្រះ | ០៩.១២ | ០៩.១៤ |
| សារណាផ្ទាល់មាត់របស់មេធាវីការពារក្ដី នួន ជា ស្នើសុំឱ្យទទួលយកឯកសារ | មេធាវីការពារក្ដី នួន ជា<br>សហព្រះរាជអាជ្ញា<br>សហមេធាវីនាំមុខ<br>មេធាវីការពារក្ដី ខៀវ សំផន | ០៩.១៦<br>០៩.២៣<br>០៩.៤១<br>០៩.៤៦ | ០៩.១៧<br>០៩.២៥<br>០៩.៤១<br>០៩.៤៦ |
| សារណាផ្ទាល់មាត់របស់មេធាវីការពារក្ដី នួន ជា ស្នើសុំឱ្យពន្យាពេលសវនាការ | មេធាវីការពារក្ដី នួន ជា<br>សហព្រះរាជអាជ្ញា | ០៩.១៦<br>០៩.២៥ | ០៩.២៣<br>០៩.៤០ |

| | | | |
|---|---|---|---|
| | សហមេធាវីនាំមុខ<br>មេធាវីការពារក្ដី ខៀវ សំផន | ០៩.៤១<br>០៩.៤៦ | ០៩.៤៦<br>០៩.៥២ |
| សារណាផ្ទាល់មាត់របស់សហព្រះរាជ-អាជ្ញាស្នើសុំឱ្យទទួលយកឯកសារ | អង្គជំនុំជម្រះ<br>សហមេធាវីនាំមុខ<br>មេធាវីការពារក្ដី នួន ជា<br>មេធាវីការពារក្ដី ខៀវ សំផន<br><br>សហព្រះរាជអាជ្ញា | ១០.១០<br>១០.១២<br>១០.១៣<br>១០.១៣<br>១០.៤៦<br>១០.៣៤ | ១០.១២<br>១០.១៣<br>១០.១៣<br>១០.៣៤<br>១០.៤៨<br>១០.៤៦ |
| អង្គជំនុំជម្រះចេញសេចក្ដីសម្រេចផ្ទាល់មាត់លើសំណើរបស់មេធាវីការក្ដី នួន ជា ក្នុងការស្នើសុំពេលវេលាបន្ថែម | អង្គជំនុំជម្រះ | ១៣.៣៦ | ១៣.៣៩ |

**<u>សេចក្ដីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

**<u>ការប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការនិងការប្រកាសពីវត្តមានរបស់ភាគី</u>**

ប្រធានអង្គជំនុំជម្រះប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ។ ក្រឡាបញ្ជីរាយការណ៍ថា គ្រប់ភាគីទាំងអស់មានវត្តមាន លើកលែងមេធាវីការពារក្ដី ខៀវ សំផន លោកស្រី Anta GUISSÉ អវត្តមានដោយមូលហេតុផ្ទាល់ខ្លួន ។ ជនជាប់ចោទ នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។

**<u>សំណើរបស់ នួន ជា សុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ</u>**

អង្គជំនុំជម្រះសម្រេចអនុញ្ញាតតាមសំណើរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមកិច្ចដំណើរការនីតិវិធីដោយផ្ទាល់ក្នុងសាលសវនាការ និងអនុញ្ញាតឱ្យគាត់តាមដានកិច្ចដំណើរការនីតិវិធីសវនាការពីបន្ទប់ឃុំខ្លួនស្ថិតនៅខាងក្រោមសាលសវនាការ។

**<u>អង្គជំនុំជម្រះបានចេញសេចក្ដីសម្រេចផ្ទាល់មាត់លើសំណើរបស់សហព្រះរាជអាជ្ញាដែលបានស្នើសុំឱ្យទទួលយកឯកសារ</u>** <u>E319/36</u>

អង្គជំនុំជម្រះបានចេញសេចក្ដីសម្រេចផ្ទាល់មាត់លើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិឱ្យទទួលយកឯកសារកំណត់ហេតុស្ដាប់ចម្លើយបន្ថែមចំនួន៩៥ គឺឯកសារ(E319/36) ដោយទទួលយកឯកសារ

E319/23.55 និង E319/23.3.56 ជាឯកសារភ័ស្តុតាង ហើយដាក់លេខសម្គាល់ឯកសារគឺ E3/9815 និង E3/9816 សម្រាប់ឯកសារទាំងនេះ ។

**<u>សារណាផ្ទាល់មាត់លើសំណើរបស់មេធាវីការពារក្តី នួន ជា ឱ្យទទួលយកឯកសារ</u>**

អង្គជំនុំជម្រះបានស្តាប់សារណាតបពីភាគីទាំងអស់ទាក់ទិនទៅនឹងសំណើរបស់មេធាវីការពារក្តី នួន ជា អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ឱ្យទទួលយកឯកសារចំនួន ២ ជាឯកសារភ័ស្តុតាង។

មេធាវីការពារក្តី នួន ជា បានរៀបរាប់ពីឯកសារទីមួយគឺថា ឯកសារពីតុលាការយោធាសម្រាប់សាក្សី 2-TCW- 816 ដែលនឹងមកផ្តល់សក្ខីកម្មនាពេលខាងមុខ ហើយឯកសារទីពីរ គឺជាឯកសារចងក្រងពីឯកសារ ស-២១ ដែលសាក្សីនេះបាន សម្ភាសន៍ជាមួយការិយាល័យចៅក្រមស៊ើបអង្កេត ហើយឯកសារទាំងពីរនេះ គឺជាប់ទាក់ទិនទៅនឹងសវនាការនេះ ។

សហព្រះរាជអាជ្ញាមិនបានជំទាស់ទៅនឹងឯកសារទីមួយទេ។ ទាក់ទងទៅនឹងការចងក្រងឯកសារ គឺមានការលើកឡើងថា វាមិនជាប់ពាក់ព័ន្ធទៅនឹងការទទួលយកឯកសារទាំងអស់នោះ នោះទេ ហើយឯកសារទាំងនោះ ត្រូវបានដាក់ដាច់ដោយឡែកពីគ្នាចូលទៅក្នុងសំណុំរឿងរួចហើយ ។ មេធាវីការពារក្តី នួន ជា បានឯកភាពចំពោះការលើកឡើងនេះ ហើយបានបញ្ជាក់ថា សំណើនេះគួរត្រូវបានដកចេញ។

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និង មេធាវីការពារក្តី ខៀវ សំផន មិនបានធ្វើការជំទាស់ទៅនឹងសំណើនេះទេ។

**<u>សារណាផ្ទាល់មាត់លើសំណើរបស់មេធាវីការពារក្តី នួន ជា ស្នើសុំពេលវេលាបន្ថែម</u>**

អង្គជំនុំជម្រះបានស្តាប់សារណាតបផ្ទាល់មាត់ ពីគ្រប់ភាគីទាំងអស់ ទាក់ទងទៅនឹងសំណើរបស់មេធាវីការពារក្តី នួន ជា ដើម្បីឱ្យអង្គជំនុំជម្រះពិចារណាចំពោះសំណើភ្លាមៗរបស់មេធាវីការពារក្តី សុំពន្យាពេលដំណើរការសវនាការ។

មេធាវីការពារក្តី នួន ជា បានលើកឡើងថា ឯកសារចំនួន ៧២៤ ក្នុងចំណោមឯកសារ ៨១៧ ដែលបានបំពេញទម្រង់មូលដ្ឋាននៃបញ្ជីឈ្មោះថ្មី ដែលរៀបចំដោយការិយាល័យសហចៅក្រមស៊ើបអង្កេត នូវចំនួនមនុស្សត្រូវបានឃុំខ្លួននៅក្នុងមន្ទីរសន្តិសុខ ស-២១ មិនត្រូវបានទទួលយកជាឯកសារភ័ស្តុតាងនោះទេ។ ទោះបីឯកសារស្ទើរតែទាំងអស់នោះ មាននៅក្នុងប្រព័ន្ធ Zylab ក៏ដោយ ប៉ុន្តែតាមការអនុវត្ត វាមានការលំបាកណាស់ដើម្បីចូលទៅយកឯកសារទាំងនោះ ។ ម្យ៉ាងវិញទៀត មេធាវីការពារក្តីបានលើកឡើងថា ខ្លួនមិនមានពេលវេលាគ្រប់គ្រាន់ ដើម្បីរៀបចំឯកសារសម្រាប់សួរសាក្សី 2-TCW-816 និង សាក្សី ឌុច នោះទេ ក្រៅពីឯកសារដែលបានទទួលយកថ្មីៗទាំងនេះ ។ មេធាវីការពារក្តីបានស្នើថា ព្រះរាជអាជ្ញា

តាំងសំណួរទៅកាន់សាក្សីទាំងពីរនៅក្នុងសប្តាហ៍នេះ ហើយបន្ទាប់មកទៀត មេធាវីការពារក្តី គួរតាំងសំណួររបស់ខ្លួន បន្ទាប់ពីចំណាយពេលបន្ថែមបីសប្តាហ៍ដើម្បីដាក់ឱ្យដំណើរការឯកសារទាំងអស់នេះ។ សហព្រះរាជអាជ្ញាបានជំទាស់ទៅនឹងកាលវិភាគសម្រាប់ការតាំងសំណួរ ដែលស្នើឡើងដោយមេធាវីការពារក្តី ដោយបញ្ជាក់ថាវាមិនបានផ្តល់ផលប្រយោជន៍នោះទេ ។ មេធាវីការពារក្តីបានលើកឡើងថា ព្រះរាជអាជ្ញាមិនបានដាក់បង្ហាញឯកសារទៅក្នុងបញ្ជីឯកសារថ្មីនោះទេ ហើយវាជាការភាន់ច្រឡំសម្រាប់មេធាវីការពារក្តីដែលបានលើកឡើងថា វាមានបញ្ហាចំពោះធនធានសម្រាប់ពួកគេ។ ជាងនេះទៅទៀត សហព្រះរាជអាជ្ញាបានលើកឡើងថា ការពន្យាពេលសវនាការ៣សប្តាហ៍នេះ គឺមានរយៈពេលយូរពេកជាពិសេស មេធាវីការពារក្តីបានសំណួរទៅសាក្សី ឌុច រួចហើយនៅក្នុងសំណុំរឿង០០១/០១ ។ សហព្រះរាជអាជ្ញាបានស្នើថា អង្គជំនុំជម្រះគួរបន្តកាលវិភាគសម្រាប់ស្តាប់សក្ខីកម្មរបស់សាក្សី និងបញ្ចប់ការស្តាប់សក្ខីកម្មរបស់សាក្សី ឌុច ពី ៩ ថ្ងៃ មកនៅត្រឹម៥ថ្ងៃ ដោយចាប់ផ្តើមពីថ្ងៃព្រហស្បតិ៍ ហើយរយៈពេល ៤ ថ្ងៃ ត្រូវបានពន្យាពេលរហូតដល់បញ្ចប់នៃវគ្គសវនាការលើអង្គហេតុ ការបោសសំអាតផ្ទៃក្នុង។

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីក៏បានលើកឡើងអំពីបញ្ហា ដែលមិនអាចចូលយកឯកសារនៅក្នុងប្រព័ន្ធ Zylab ។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងថា បញ្ជីថ្មីគឺមានសារៈសំខាន់ណាស់សម្រាប់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ហេតុដូចនេះ ស្នើឱ្យអង្គជំនុំជម្រះ ដោះស្រាយបញ្ហានេះ។ ទាក់ទងនឹងកាលវិភាគសវនាការដែលបានលើកឡើងដោយមេធាវីការពារក្តី សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា ខ្លួនគួរពឹងផ្អែកទៅលើការសម្រេចរបស់អង្គជំនុំជម្រះ។

មេធាវីការពារក្តី ខៀវ សំផន ក៏បានលើកឡើងថា ខ្លួនមិនមានពេលវេលាគ្រប់គ្រាន់ ដើម្បីមើលឯកសារទាំងអស់នោះទេ ហើយថា មេធាវីការពារក្តីដែលស្នើសុំពន្យាពេលសវនាការសម្រាប់រយៈពេល៣សប្តាហ៍ គឺជាការសមរម្យបំផុត។

**<u>សារណាផ្ទាល់មាត់លើសំណើរបស់សហព្រះរាជអាជ្ញាឱ្យទទួលយកឯកសារ</u>**

អង្គជំនុំជម្រះបានស្តាប់សារណាតបផ្ទាល់មាត់ពីភាគីទាំងអស់ ទាក់ទងទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា ស្របតាមវិធាន ៨៧ (៤) នៃវិធានផ្ទៃក្នុង ឱ្យទទួលយកឯកសារកំណត់ហេតុស្តាប់ចម្លើយ និងឯកសារផ្សេង ដែលជាឯកសារភ័ស្តុតាង ដែលបានស្នើឡើងនៅនៅក្នុងឯកសារ E319/47 ។

សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីជឿជាក់លើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះទៅលើសំណើនេះ ។ ចំពោះ មេធាវីការពារក្តី នួន ជា វិញ មិនមានការកត់សំគាល់អ្វីនោះទេ ។

មេធាវីការពារក្តី ខៀវ សំផន បានជំទាស់ទៅនឹងការទទួលយកឯកសារចំនួន ៤០ ដែលឯកសារទាំងនោះ មិនមែនជាសក្ខីកម្មអាទិភាពសម្រាប់សួរសាក្សីទាំងនោះទេ។ មេធាវីការពារក្តី បានបញ្ជាក់ទៀតថា សហព្រះរាជអាជ្ញា មិនបានផ្តល់ការពន្យល់ណាមួយចំពោះការធ្វើសំណើនេះទេ រហូតមកដល់ នៅពេល ដែលពួកគេបានដឹង កាលពីឆ្នាំកន្លងទៅ ។ មេធាវីការពារក្តីបានបញ្ជាក់ថា ឯកសារទាំងអស់នោះមិនបាន ស្វែងរកការពិតនោះទេ ព្រោះថា ដោយសារតែវាត្រូវទទួលយកជំនួសការផ្តល់សក្ខីកម្មដោយផ្ទាល់របស់ សាក្សី ។

ជាការឆ្លើយតប សហព្រះរាជអាជ្ញាបានគូសបញ្ជាក់ថា អង្គជំនុំជម្រះ មិនអាចស្តាប់សក្ខីកម្មរបស់សាក្សី ដែលពាក់ព័ន្ធទាំងអស់នោះទេ ហេតុដូចហើយ បានជាពួកគេស្នើសុំឱ្យទទួលយកកំណត់ហេតុនៃការ ស្តាប់ចម្លើយសាក្សី ជំនួសឱ្យការស្តាប់សក្ខីកម្មរបស់សាក្សីវិញ។ ជាចុងក្រោយ ដើម្បីឆ្លើយតបទៅនឹង ការលើកឡើងចំពោះពេលវេលា សហព្រះរាជអាជ្ញាបានគូរបញ្ជាក់ថា កំណត់ហេតុនៃការស្តាប់ចម្លើយ សាក្សី ត្រូវបានដាក់បង្ហាញតាំងពីមុនមកនៅចំពោះមុខភាគីទាំងអស់ ។ សហព្រះរាជអាជ្ញាបានធ្វើការ សន្និដ្ឋានថា ខ្លួនមិនបានរួមបញ្ចូលកំណត់ហេតុនៃការស្តាប់សម្លើយសាក្សីនៅក្នុងសំណើនោះទេ ហើយ ភាគីខ្លួនឯងផ្ទាល់ គួរតែធ្វើសំណើធម្មតាដើម្បីទទួលយកឯកសារពាក់ព័ន្ធ ស្របតាមវិធាន ៧៨ (៤) នៃវិធានផ្ទៃក្នុង ។

**<u>សំណើផ្ទាល់មាត់លើសំណើរបស់មេធាវីការពារក្តី នួន ជា ដើម្បីពិចារណាទៅនឹងការពន្យាពេលធ្វើសវនា-ការមុនពេលកំណត់</u>**

អង្គជំនុំជម្រះបានសម្រេចពន្យាពេលធ្វើសវនាការរហូតដល់ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១៦ ក្រោយពី មានសំណើរបស់មេធាវីការពារក្តី នួន ជា ឱ្យមានការរៀបចំកាលវិភាគធ្វើសវនាការឡើងវិញ ដើម្បីទទួល យកពេលវេលាបន្ថែមក្នុងការរៀបចំសំណួរដេញដោលដល់សាក្សី 2-TCW-816 និង សាក្សី ឌុច ។ ទាក់ទង ទៅនឹងកាលវិភាគសវនាការដែលបានកែសម្រួល ត្រូវបានជូនដំណឹងតាមរយៈអ៊ីម៉ែលដល់ភាគីទាំងអស់ ហើយអង្គជំនុំជម្រះបានបដិសេធទៅនឹងសំណើផ្សេងទៀតរបស់ភាគី ទាក់ទងទៅនឹងកាលវិភាគសវនាការ នេះ ។

New E3s

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/9815 | E319/23.3.55 | 01065124-01065134; 01079243-01079252; / | Written Record of Interview witness SUOS Thy | C | / | / | / |
| E3/9816 | E319/23.3.56 | 01065135-01065146; 01079243-01079252 / | Written Record of Interview witness SUOS Thy | C | / | / | / |

**<u>ដីកា/សេចក្ដីសម្រេចផ្ទាល់មាត់៖</u>**

- អនុញ្ញាតឱ្យជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរការនីតិវិធីសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ហើយបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា ដើម្បីបន្តសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។ (០៩.១០)
- សេចក្ដីសម្រេចផ្ទាលើមាត់ឱ្យទទួលយកឯកសារ E319/23.4.55 និង E319/23.4.56 ជាឯកសារភ័ស្ដុតាង និងដាក់លេខសម្គាល់ E3 numbers, E3/9815 និង E3/9816។ (០៩.១៥)
- សេចក្ដីសម្រេចផ្ទាល់មាត់ឱ្យពន្យាពេលធ្វើសវនាការរហូតដល់ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១៦។ (១៣.៣៩)
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំខ្លួនពួកគាត់ត្រឡប់មកកាន់សាលសវនាការវិញឱ្យបានមុនម៉ោង ៩.00 ព្រឹក នៅថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១៦។ (១៣.៤០)

| **<u>កាលវេលាសវនាការបន្ត</u>** |
| --- |
| សវនាការនឹងបន្តទៅថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១៦ ចាប់ផ្តើមពីម៉ោង ០៩.០០ ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៦

ក្រឡាបញ្ជី ក្រឡាបញ្ជី

លោក [illegible] [illegible] Roger PHILLIPS